# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


១២-៨-២០១៥ -ព្រះរាជក្រម នស/រកម/០៨១៥/០១០ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ៦៦០៧


### ២~ព្រះរាជក្រឹត្យ


២៨-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៧៣ ស្តីពី ការបំពាក់ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី ជូនឯកឧត្តម **គង់ ឌីលីន** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៦៦២១

២៨-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៧៤ ស្តីពី ការដាក់លោក **កេត លីសុត្ថា** ឱ្យចូលនិវត្តន៍ ក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រី សុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ៦៦២២

២៨-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៧៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈជូនសពលោកវរសេនីយ៍ឯក **ឆេន ឈួត** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៦៦២៣

២៨-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៧៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២៥ រូប ៦៦២៤

២៨-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៧៧ ស្តីពី ការតែងតាំងឯកឧត្តម **ហម ច្រឹង** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ៦៦២៦

២៨-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៧៨ ស្តីពី ការតែងតាំងឯកឧត្តម **កុយ សារឿន** ជាទីប្រឹក្សារដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៦២៧

២៨-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៧៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វីរះពុចុង វ៉ារ៉ូដុម** (VIRAPUCHONG VARODOM) ជនជាតិថៃ សញ្ជាតិថៃ ៦៦២៨

២៨-៧-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ូ ឈាវអ៊ី** (SU QIAOYI) ជនជាតិចិន សញ្ជាតិចិន ៦៦២៩

| | | |
|---|---|---|
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់កញ្ញា **លូ ឈី** (LYU QI) ជនជាតិចិន សញ្ជាតិចិន | ៦៦៣០ |
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **យាន ជីនភីង** (YAN JINPING) ជនជាតិចិន សញ្ជាតិចិន | ៦៦៣១ |
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ូ លាំង** (XU LIANG) ជនជាតិចិន សញ្ជាតិចិន | ៦៦៣២ |
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ដល់លោក **ប៊ែនហាតដ៍ លូកា** (BERNHARDT LUKAS) ជនជាតិស្វីស សញ្ជាតិស្វីស | ៦៦៣៣ |
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ លោក **ប៉ែន សុជាតិ** | ៦៦៣៤ |
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ១០ រូប | ៦៦៣៥ |
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និងលោកស្រី ចំនួន ២៦ រូប | ៦៦៣៦ |
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម **ប៊ិន សម្បត្តិថារ័ត្ន** | ៦៦៣៧ |
| ២៨-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៨៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ ប្រគេនចំពោះ ព្រះតេជគុណ **សន ស៊ាន** | ៦៦៣៨ |
| ២៩-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៩០ ស្តីពី ការតែងតាំងឯកឧត្តម **រុន ពណ្ណារិទ្ធ** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន | ៦៦៣៩ |
| ២៩-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៩១ ស្តីពី ការតែងតាំងទីប្រឹក្សា សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២ រូប ដោយមិនយកប្រាក់បៀវត្ស | ៦៦៤០ |
| ២៩-៧-២០១៥ | -ព្រះរាជក្រឹត្យ នស/រកត/០៧១៥/៧៩២ ស្តីពី ការតម្លើងឋានៈឯកឧត្តមឧត្តមសេនីយ៍ទោ **សាយ ឆាន** ជំនួយការ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក | ៦៦៤១ |

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៧-៨-២០១៥ -អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៦៤២

០៧-៨-២០១៥ -អនុក្រឹត្យលេខ ១០៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៦៤៤

០៧-៨-២០១៥ -អនុក្រឹត្យលេខ ១០៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៦៤៦

១០-៨-២០១៥ -អនុក្រឹត្យលេខ ១០៦ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ៦៦៤៨

១៦-៧-២០១៥ -អនុក្រឹត្យលេខ ៧៨៦ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦៦៦១

១៧-៧-២០១៥ -អនុក្រឹត្យលេខ ៧៨៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៦៦២

១៧-៧-២០១៥ -អនុក្រឹត្យលេខ ៧៨៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៦៦៣

១៧-៧-២០១៥ -អនុក្រឹត្យលេខ ៧៨៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៦៦៤

១៧-៧-២០១៥ -អនុក្រឹត្យលេខ ៧៩០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៦៦៥

១៧-៧-២០១៥ -អនុក្រឹត្យលេខ ៧៩១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៦៦៧

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៨-៧-២០១៥ -ប្រកាសរួមលេខ ៧១៧ សហវ.ប្រក ស្តីពី ការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ៦៦៨១

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

១៩-៥-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ២២២ ឧស.កឧ.ប្រក.០៥ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជូ ហួយ ហ្វ៊ុតវ៉េ បង្កើតសាខារោងចក្រ ផលិតស្បែកជើង ៦៧១៤

១៩-៥-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ២២៣ ឧស.កឧ.ប្រក.០៥ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីនរី អ៊ិនវេសមេន (ខេមបូឌា) បង្កើតរោងចក្រ កែច្នៃដំឡូងមី សណ្តែកដី និងគ្រាប់ស្វាយចន្ទី ៦៧១៧

១៩-៥-២០១៥ -ប្រកាសបង្កើតរោងចក្រលេខ ២២៤ ឧស.កឧ.ប្រក.០៥ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ ៦៧២០

# ព្រះរាជក្រម

នស/រកម/០៨១៥/០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៦/០០៤/២០១៥ កបធ.ច ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានាការពារសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ ព្រមទាំងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់បែបបទទទួលស្គាល់តាមផ្លូវច្បាប់ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកំណត់ទំនាក់ទំនងរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានបទប្បញ្ញត្តិច្បាប់ដោយឡែក ដែលចែងផ្សេងពីនេះ ។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ៖

- សមាគមក្នុងស្រុក សំដៅដល់អង្គការសមាជិកភាព ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជា ដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួន ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា ។

- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក សំដៅដល់អង្គការមិនមែនសមាជិកភាពរួមទាំងមូលនិធិដែលត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជា ដោយរូបវន្តបុគ្គល ឬ/និងនីតិបុគ្គល ក្នុងគោលបំណងផ្តល់មូលនិធិ ឬសេវាកម្មលើវិស័យមួយ ឬច្រើនដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា ។

- សមាគមបរទេស ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស សំដៅដល់អង្គការស្របច្បាប់ដែលបង្កើតឡើងនៅក្រៅប្រទេស ក្នុងគោលបំណងធ្វើសកម្មភាពដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ។

- សមាគម សំដៅដល់សមាគមក្នុងស្រុក និងសមាគមបរទេស ។

- អង្គការមិនមែនរដ្ឋាភិបាល សំដៅដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ។

## ជំពូកទី ២
## ការបង្កើត និងការចុះបញ្ជីសមាគម និង
## អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

**មាត្រា ៥.-**

ការបង្កើតសមាគមក្នុងស្រុកតម្រូវឲ្យមានសមាជិកស្ថាបនិក ដែលជារូបវន្តបុគ្គលចំនួនយ៉ាងតិច ៣ (បី) រូប ដែលមានអាយុគ្រប់ ១៨(ដប់ប្រាំបី)ឆ្នាំ ឡើងទៅ ។

ការបង្កើតអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក តម្រូវឲ្យមានសមាជិកស្ថាបនិក ដែលជារូបវន្តបុគ្គលសញ្ជាតិខ្មែរចំនួនយ៉ាងតិច ៣ (បី) រូប ដែលម្នាក់ៗមានអាយុគ្រប់ ១៨ (ដប់ប្រាំបី)ឆ្នាំ ឡើងទៅ ។

**មាត្រា ៦.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដោយបំពេញសំណុំលិខិតដូចខាងក្រោម ៖

១-ពាក្យសុំចុះបញ្ជីចំនួន ២( ពីរ ) ច្បាប់

២-លិខិតបញ្ជាក់អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីមេឃុំ ឬចៅសង្កាត់ចំនួន ១( មួយ )ច្បាប់

៣-ជីវប្រវត្តិរបស់ស្ថាបនិកម្នាក់ៗមានបិទរូបថតបច្ចុប្បន្នទំហំ ៤គុណនឹង៦ ចំនួន ២(ពីរ)ច្បាប់

៤-លក្ខន្តិកៈចុះហត្ថលេខាដោយប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ចំនួន ២( ពីរ ) ច្បាប់ ។

**មាត្រា ៧.-**

លក្ខន្តិកៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាន ហើយត្រូវចែងចំណុចសំខាន់ៗដូចខាងក្រោម ៖

១-គោលបំណង និងគោលដៅ

២-ឈ្មោះជាអក្សរពេញ អក្សរកាត់ ដោយមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញ អក្សរកាត់របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីមុនរួចហើយ

៣-សញ្ញាសម្គាល់ មិនត្រូវចម្លងតាមសញ្ញាជាតិ ឬស្ថាប័នរដ្ឋ ឬរូបសញ្ញារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីមុនរួចហើយ ឬរូបសញ្ញាបដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិ

៤-វិធាននៃការជ្រើសរើស ការបញ្ឈប់ ការបណ្តេញចេញ ការផ្លាស់ប្តូរ ការដកហូតតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ

៥-វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ

៦-ប្រភពធនធាន និងទ្រព្យសម្បត្តិ

៧-វិធាននៃការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ

៨-វិធាននៃការរំលាយ វិធាននៃការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ ។

**មាត្រា ៨.-**

ក្រសួងមហាផ្ទៃត្រូវពិនិត្យសំណុំលិខិតស្នើសុំរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ហើយត្រូវសម្រេចព្រមទទួល ឬមិនព្រមទទួលចុះបញ្ជីរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ។

ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឲ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ ៤៥(សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ។ ក្រសួងមហាផ្ទៃត្រូវសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតកែតម្រូវ ។

ក្នុងករណីក្រសួងមហាផ្ទៃខកខានមិនបានសម្រេចអំពីការចុះបញ្ជីក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវចាត់ទុកថា បានទទួលការចុះបញ្ជីស្របតាមច្បាប់នេះ ។ ក្នុងករណីនេះ ក្រសួងមហាផ្ទៃត្រូវធ្វើនិយតកម្មឯកសារចុះបញ្ជីផ្តល់ជូនទៅសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ។

ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានរកឃើញថា មានគោលបំណង និងទិសដៅដែលអាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលក្រសួងមហាផ្ទៃសម្រេចបដិសេធចំពោះការស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងទៅតុលាការ ។

**មាត្រា ៩.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នឹងក្លាយជានីតិបុគ្គល ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជី ។ ក្រសួងមហាផ្ទៃត្រូវចម្លងឯកសារចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនេះទៅក្រសួងស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានចុះបញ្ជី មិនត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

ROYAUME DU CAMBODGE · LE SECRETARIAT DU PALAIS ROYAL

**មាត្រា ១០.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ ។

**មាត្រា ១១.-**

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសម្រាប់នីតិបុគ្គលនិងសម្រាប់ជនបរទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគមសម្រាប់អនីតិជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## ការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស

**មាត្រា ១២.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមទម្រង់ជាការចុះអនុស្សរណៈ ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងអនុវត្តគម្រោងរយៈពេលខ្លី ត្រូវសុំការអនុញ្ញាតពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដោយផ្ទាល់ ឬតាមរយៈដៃគូក្នុងស្រុក ។

**មាត្រា ១៣.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងអនុវត្តគម្រោងនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំចុះអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការ

អន្តរជាតិ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម៖

១-លិខិតរបស់ប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានទីស្នាក់ការអចិន្ត្រៃយ៍របស់ខ្លួននៅបរទេស ស្នើតែងតាំងតំណាងរបស់ខ្លួនដោយភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលស្នើតែងតាំងចំនួន ១ (មួយ) ច្បាប់ និងស្នើបើកទីស្នាក់ការតំណាងចំនួន ១ (មួយ) ច្បាប់

២-លិខិតបញ្ជាក់អាសយដ្ឋាន នៃទីស្នាក់ការតំណាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីមេឃុំ ឬចៅសង្កាត់ចំនួន ១ (មួយ) ច្បាប់

៣-លិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ចប្រទេសដើម អនុញ្ញាតឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដំណើរការចំនួន ១ (មួយ) ច្បាប់

៤-លិខិតគាំទ្រគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ចេញដោយអាជ្ញាធរសាធារណៈនៃព្រះរាជាណាចក្រកម្ពុជាចំនួន ១ (មួយ) ច្បាប់

៥-លិខិតបញ្ជាក់ពីចំនួនថវិកាសម្រាប់អនុវត្តគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស រយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែ បញ្ជាក់ដោយទីស្នាក់ការអចិន្ត្រៃយ៍ខ្លួននៅបរទេសចំនួន ១ (មួយ) ច្បាប់

៦-លិខិតសន្យាផ្ដល់នូវពល់គណនីនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ១ (មួយ) ច្បាប់ ។

**មាត្រា ១៤.-**

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យខ្លឹមសារនៃសំណុំលិខិត ហើយត្រូវសម្រេចយល់ព្រម ឬមិនយល់ព្រមចុះអនុស្សរណៈជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ។

**មាត្រា ១៥.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវធ្វើការពិភាក្សាឯកភាពជាមួយអាជ្ញាធរសាធារណៈដែលជាដៃគូលើគម្រោងនានា មុននឹងដាក់ពាក្យសុំចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានចែងក្នុងចំណុចទី ៤ នៃមាត្រា ១៣ នៃច្បាប់នេះ ។

**មាត្រា ១៦.-**

អនុស្សរណៈមានសុពលភាពរយៈពេលយ៉ាងយូរ ៣ (បី) ឆ្នាំ ដោយផ្អែកតាមគម្រោងនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ។ សុពលភាពអនុស្សរណៈនឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិក្រោយថ្ងៃផុតកំណត់ ។

ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស មានបំណងបន្តសុពលភាពអនុស្សរណៈ ត្រូវដាក់ពាក្យសុំបន្តសុពលភាពអនុស្សរណៈឲ្យបាន ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃផុតសុពលភាពអនុស្សរណៈ ។

**មាត្រា ១៧.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈរួចហើយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការ តំណាង ឬតំណាងប្រចាំប្រទេស ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃដែលផ្លាស់ប្តូរ ឬប្រែប្រួល ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ ។

## ជំពូកទី ៤

## ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ១៨.-**

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគមក្នុងស្រុក មានដូចខាងក្រោម ៖

- ភាគទាន ឬវិភាគទាន ឬបរិសទានរបស់សមាជិក
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត ។

ធនធាន និងទ្រព្យសម្បត្តិរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានដូចខាងក្រោម៖

- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់អង្គការ
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត ។

**មាត្រា ១៩.-**

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវបានមកពីប្រភពស្របច្បាប់នានា ។

## ជំពូកទី ៥
## សិទ្ធិ ផលប្រយោជន៍ និងភារកិច្ចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ២០.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬអនុស្សរណៈ ត្រូវស្ថិតនៅក្រោមនីតិរូបនៃរបបសារពើពន្ធជាធរមាន និងទទួលបានការលើកទឹកចិត្តនិងការអនុគ្រោះនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ២១.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ មានសិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិការជាមួយដៃគូក្នុងការអនុវត្តគម្រោងសកម្មភាព ស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២២.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ មានសិទ្ធិជ្រើសរើសបុគ្គលិក ឬកម្មករដើម្បីបម្រើការងារ ។ ការជ្រើសរើសនេះត្រូវអនុវត្តតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-**

ទីស្នាក់ការតំណាងរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស បុគ្គលិកបរទេស និងបុគ្គលិកខ្មែរ រួមទាំងសមាជិកក្រុមគ្រួសាររបស់ខ្លួន ពុំទទួលបានអភ័យឯកសិទ្ធិនិងបុព្វសិទ្ធិជាអ្នកការទូតដូចមានចែងក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ ១៩៦១ ស្តីពីទំនាក់ទំនងការទូតឡើយ ទាក់ទងនឹងសកម្មភាពបំពេញមុខងាររបស់ខ្លួន និងរឿងក្តីគ្រប់ប្រភេទ លើកលែងតែមានកិច្ចព្រមព្រៀងពិសេសរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ។

**មាត្រា ២៤.-**

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៥.-**

អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ មិនឲ្យហួសពីថ្ងៃចុងខែកុម្ភៈនៃឆ្នាំបន្ទាប់ ។ ក្នុងករណីដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិន

ROYAUME DU CAMBODGE LE MINISTERE du PALAIS ROYAL

មែនរដ្ឋាភិបាលក្នុងស្រុកនោះត្រូវផ្ញើរបាយការណ៍ខាងលើ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយ ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើម ឲ្យបានក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច ៥(ប្រាំ) ឆ្នាំ ។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចស្នើសុំរបាយការណ៍ស្តីពីសកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់សមាគម ។

អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ចម្លងពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងគ្រប់ឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១ (មួយ) ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើមឲ្យបានក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។

ក្នុងករណីចាំបាច់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។

## ជំពូកទី ៦
## ការផ្អាកសកម្មភាព ការរំលាយ ការបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ២៦.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចផ្អាកសកម្មភាពរបស់ខ្លួន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ។ មុននឹងផ្អាកសកម្មភាព សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៥ នៃច្បាប់នេះ ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធីនិងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ២៧.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អាចផ្អាកសកម្មភាពបានដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ មុននឹងផ្អាកសកម្មភាព សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវធ្វើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ២៥ នៃច្បាប់នេះ ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស មុននឹងបញ្ចប់សុពលភាពអនុស្សរណៈត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ២៨.-**

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិដែលនៅសល់ពីការជម្រះកាតព្វកិច្ច ត្រូវអនុវត្តតាមលក្ខន្តិកៈរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិដែលនៅសល់ពីការជម្រះកាតព្វកិច្ច ត្រូវអនុវត្តតាមអនុស្សរណៈ ឬកិច្ចព្រមព្រៀងជាមួយម្ចាស់ជំនួយ ។

**មាត្រា ២៩.-**

ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានរំលាយ ដោយសេចក្តីសម្រេចរបស់តុលាការ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីដោយសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ការជម្រះកាតព្វកិច្ច ព្រមទាំងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិដែលនៅសល់ ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលត្រូវបានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រេចបញ្ចប់សុពលភាពអនុស្សរណៈមុនកាលកំណត់ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានស្នើសុំបើកទីស្នាក់ការតំណាងនៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៧
## ទណ្ឌកម្មរដ្ឋបាល និងទោសប្បញ្ញត្តិ

**មាត្រា ៣០.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តតាមមាត្រា ១០ ឬមាត្រា ២៤ ឬកថាខណ្ឌទី ១ ឬកថាខណ្ឌទី ២ នៃមាត្រា ២៥ នៃច្បាប់នេះ ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ។ ក្នុងករណីមិនអនុវត្តតាមការជូនដំណឹង ក្រសួងមហាផ្ទៃត្រូវជូនដំណឹង ជាលាយលក្ខណ៍អក្សរផ្អាកសកម្មភាពជា

បណ្តោះអាសន្នរយៈពេលយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ ។ ក្នុងករណីនៅតែមិនព្រមអនុវត្ត ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានអនុវត្តត្រឹមត្រូវតាមលក្ខន្តិកៈរបស់ខ្លួន ក្រសួងមហាផ្ទៃត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ដោយទុករយៈពេលយ៉ាងយូរ ៣០(សាមសិប) ថ្ងៃ ។ ក្នុងករណីនៅតែមិនព្រមអនុវត្ត ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី ។

ក្រសួងមហាផ្ទៃត្រូវសម្រេចលុបឈ្មោះចេញពីបញ្ជីចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៣១.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃទាក់ទងនឹងការមិនចុះបញ្ជី ការបញ្ឈប់សកម្មភាព ការលុបឈ្មោះចេញពីបញ្ជី និងការពិន័យទៅតុលាការ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេច ។

**មាត្រា ៣២.-**

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្នុងករណីមិនរាងចាល សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ត្រូវពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ដោយក្រសួងមហាផ្ទៃ ។ ក្នុងករណីនៅតែបន្តធ្វើសកម្មភាពបន្តទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមច្បាប់ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណា ដែលត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជី ឬផ្អាកសកម្មភាព ហើយនៅតែបន្តធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៣.-**

ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមិនបានអនុវត្តតាមមាត្រា ១៧ ឬមាត្រា ២៤ ឬកថាខណ្ឌទី៣ នៃមាត្រា ២៥ នៃច្បាប់នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ ។ ក្នុងករណីមិនអនុវត្ត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន ក្រសួង

ការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវសម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សរណៈ ។

**មាត្រា ៣៤.-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសណាដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ វិធានការបន្ថែមទាក់ទង នឹងការបណ្តេញចេញស្របតាមច្បាប់អន្តោប្រវេសន៍ អាចត្រូវបានអនុវត្តចំពោះជនបរទេសណា ដែលបម្រើការងារនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលប្រព្រឹត្តល្មើសខាងលើ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៣៥.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបញ្ចប់សុពលភាពអនុស្សរណៈ ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អនុវត្តមិនបានត្រឹមត្រូវតាមអនុស្សរណៈដែលចុះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ។

**មាត្រា ៣៦ .-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណា ដែលសកម្មភាពរបស់ខ្លួនធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ឬមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម ឬបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៧.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំលិខិតនៅក្រសួងមហាផ្ទៃរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជី និងទទួលបានជាស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គលស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៨.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ ត្រូវចាត់ទុកថាបានចុះបញ្ជីស្របតាមច្បាប់នេះ និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៣៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកម.០៨១៥.០១៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ហត្ថលេខា**
**សម្តេចក្រឡាហោម ស ខេង**

លេខ: ៩៤៨ ស.ណ
**សំណៅដែលមានតម្លៃជាឯការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៧៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បំពាក់ឋានន្តរស័ក្តិ**ឧត្តមសេនីយ៍ត្រី** ជូនឯកឧត្តម **គង់ ឆីលីន** អត្តលេខ ៥៤៦៩៤ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៥០៧. ៧៩០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ: ៧២៧ ស.ណ
**សំណៅចែលមានតម្កល់ខាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ដាក់ លោក **ភេត លីសុគ្គា** ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ របស់ក្រសួងសុខាភិបាល ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៥០៧.៧៨១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥*

លេខៈ ៥០៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/ ៧៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈជូនសពលោកវរសេនីយ៍ឯក **ឆេន ឈួត** អត្តលេខ ០២៨៩៧ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣៧.១៥០៧.៧៨២

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

លេខ: ៥.០០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៧៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ឯក **កែវ ចំរើន** អត្តលេខ ០០៥៣៣
២- លោកវរសេនីយ៍ឯក **អ៊ិន ជីវ៉ា** អត្តលេខ ០០៧១៥
៣- លោកវរសេនីយ៍ឯក **ណុប គឹមហេង** អត្តលេខ ០០៩៤៥
៤- លោកវរសេនីយ៍ឯក **ទេព សុវណ្ណដារ៉ា** អត្តលេខ ០១៦២៥
៥- លោកវរសេនីយ៍ឯក **ជេត វណ្ណនី** អត្តលេខ ០១២៥៤
៦- លោកវរសេនីយ៍ឯក **លី វីរៈ** អត្តលេខ ០១៧៧៦
៧- លោកវរសេនីយ៍ឯក **គោគ សុខុន** អត្តលេខ ០១៨៣៧
៨- លោកវរសេនីយ៍ឯក **ហែម សាបាន** អត្តលេខ ០១៨៤៩
៩- លោកវរសេនីយ៍ឯក **ជរ ហេង** អត្តលេខ ០១៩៨៦
១០- លោកវរសេនីយ៍ឯក **ចាន់ សារឿន** អត្តលេខ ០២០០៨
១១- លោកវរសេនីយ៍ឯក **ធឿន ណារ៉ា** អត្តលេខ ០២០១០
១២- លោកវរសេនីយ៍ឯក **ប៊ិច សោមសាខន** អត្តលេខ ០២០៣៤
១៣- លោកវរសេនីយ៍ឯក **អ៊ុំ តី** អត្តលេខ ០២០៣៧

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១៤- លោកវរសេនីយ៍ឯក **ឯម រដ្ឋា** អត្តលេខ ០២១៦៨
១៥- លោកវរសេនីយ៍ឯក **ជិន ចិន្ដា** អត្តលេខ ០២៥៩២
១៦- លោកវរសេនីយ៍ឯក **យឹម សុភាស់** អត្តលេខ ០៣៧០៤
១៧- លោកវរសេនីយ៍ឯក **ឆាយ ភន** អត្តលេខ ០៣៧៣៣
១៨- លោកវរសេនីយ៍ឯក **តូច យ៉ុន** អត្តលេខ ០៣៨៣៨
១៩- លោកវរសេនីយ៍ឯក **អ៊ុំ អមរ៉ា** អត្តលេខ ០៥៧៧២
២០- លោកវរសេនីយ៍ឯក **ពេជ្រ សុភ្ជារ័ត្ន** អត្តលេខ ០៥៩៣២
២១- លោកវរសេនីយ៍ឯក **សោម មុរ៉ា** អត្តលេខ ០៧៩៨២
២២- លោកវរសេនីយ៍ឯក **ចាន់ ចន** អត្តលេខ ១២១៦៧
២៣- លោកវរសេនីយ៍ឯក **យិន ចំណាន** អត្តលេខ ១២១៦៩
២៤- លោកវរសេនីយ៍ឯក **ម៉ៅ វ៉ៃ** អត្តលេខ ១២១៧៨
២៥- លោកវរសេនីយ៍ឯក **ឈឿន សុចិត្ត** អត្តលេខ ៥៣៨៤៩។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ថ្ងៃ ១៥០៧-៧៤៦១*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥*

លេខៈ ៩០១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង ឯកឧត្តម **ហាម ច្រឹន** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពស៧.១៥០៣.៧៧៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

លេខៈ ៧៩៩ ស.ណ
**សំណៅដែលមានគម្លៀជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៧៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **កុយ សារឿន** ជាទីប្រឹក្សារដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៥០៧.៧៩៥

លេខៈ ៧២៩ ស.ណ
**សំណៅដែលមានអត្ថប្រយោជន៍ចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា, ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥*

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៦៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **វីរៈពូឈុង វ៉ារ៉ូដុម** (VIRAPUCHONG VARODOM) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៦៧ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣.១៥០៧.៧៨៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

លេខ: ៧៩២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/ ៧៨០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ូ ឈាវអ៊ី** (SU QIAOYI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៨៦ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥០៧. ៧៨៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ:៧៩៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែកក្កដា,ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៨១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **លូ ឈី** (LYU QI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៨៨ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពារ.១៥០៧.៧៨៨

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ:៧៩៤ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/ ៧៨២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យាន ជីនភីង** (YAN JINPING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៧៧ នៅខេត្តជាំងស៊ី សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥០៧. ៧៨៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៥*

លេខៈ៧៩០ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៨៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ូ លាំង** (XU LIANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៩ នៅខេត្តជាំងស៊ុ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ស៊ូ រ៉ាហ្វែល** (HSU RAFAEL)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥០៧. ៧៨០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

លេខ: ៧៩៣ ស.ណ
**សំណៅចែចែងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៨៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **ប៊ែនហាតដ៍ លូកា** (BERNHARDT LUKAS ) ជនជាតិស្វីស សញ្ជាតិស្វីស កើតថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៧ នៅខេត្តប៊ុឡាក ប្រទេសស្វីស។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៥០៧. ៧៩១

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ:៧៨៩ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៨៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**ដល់**

**គ្រឿងឥស្សរិយយស ជាតូបការ :**

លោក ប៉ែន សុជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ព.រ.ក-១៥០៧-៧៨៥

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ:៨០៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៨៦

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- វរសេនីយ៍ឯក ហេង សាម៉ាច អត្តលេខ ០០១៩២៦

២- វរសេនីយ៍ទោ ប្រាក់ សុខា អត្តលេខ ០០៨៧៣៥

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- វរសេនីយ៍ត្រី ផុន ដាន់ណា អត្តលេខ ០៤៤៩៣៤

២- វរសេនីយ៍ត្រី នួន ប៊ុណ្ណា អត្តលេខ ០៦១៣២០

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- អនុសេនីយ៍ឯក អ៊ុក ប៊ុនថា អត្តលេខ ០២២៨៧២

២- អនុសេនីយ៍ឯក ហេង តារា អត្តលេខ ០៥៨៧៥៩

៣- អនុសេនីយ៍ឯក ញ៉ឹង រ៉ាយ៉ុន អត្តលេខ ០២៥៨៩៩

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

- អនុសេនីយ៍ទោ ហេង ស៊ីនឿន អត្តលេខ ១៦២៧៨៥

ង-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ :

- វរសេនីយ៍ឯក ហាស សុភារិទ្ធ អត្តលេខ ០១៦០៥៨

ច-គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់ មាស ០២គ្រឿង ថ្នាក់ ប្រាក់ ០២គ្រឿង ថ្នាក់ សំរិទ្ធ ០២គ្រឿង :

- ឧត្តមសេនីយ៍ត្រី សេង ឫទ្ធី អត្តលេខ ០០៤១២៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១៥០៧.៧៩៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

លេខ: ៨០៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/ ៧៨៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

### ដូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម ជ័យ វុឡី
២-ឯកឧត្តម សរ មុយលី
៣-ឯកឧត្តម ធន់ សារីម
៤-ឯកឧត្តម សោម បូរ៉ា
៥-លោក កង សុវណ្ណ
៦-លោក ត្រី ចំរើន

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម ទន់ សាវ៉ាត
២-ឯកឧត្តម នុត ឈឿង
៣-ឯកឧត្តម ឈិន យូន
៤-ឯកឧត្តម ប៉ាង ណាត
៥-ឯកឧត្តម ស៊ី ច័ន្ទតារា
៦-ឯកឧត្តម លុក ប៊ុណ្ណារដ្ឋ
៧-លោក ជ័យ សោភា
៨-លោក នុត បូផាន់

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

-ឯកឧត្តម ពៅ គីមច័ន្ទវ័ត្ន

**ឃ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរត្ន ថ្នាក់ មហាសេនា :**

១-ឯកឧត្តម តន់ យ៉ាន
២-ឯកឧត្តម ឡុង សេង
៣-ឯកឧត្តម យឿន នរ៉ា

**ង-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១-ឯកឧត្តម សោម សាត
២-ឯកឧត្តម ប៊ូ វណ្ណារិទ្ធ
៣-ឯកឧត្តម មូង សុវត្ថិ
៤-លោកស្រី រស់ កណ្តាវី
៥-លោក ជៀង យ៉ារ៉េត
៦-លោក ហៃម វណ្ណារិទ្ធ
៧-លោក សុខ ជា

**ច-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរត្ន ថ្នាក់ អស្សឫទ្ធិ :**

-លោក ម៉ម ឈឿម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧. ១៥០៧. ៧៩៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

លេខ ៥០៧ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/ ៧៨៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

**-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

ឯកឧត្តម **ប៊ិន សម្បត្តិថាវ័ត្ត**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៥០៧.៧៩៥

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥*

លេខ: ៨០៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៧៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ :**

ព្រះតេជគុណ **សន សៀន**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

រកត. ១៥០៧. ៧៧៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥

លេខ: ៩០៥ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៦០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **រុន ពណ្ណារិទ្ធ** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៧១៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៨/៧ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៣៣. ១៥០៧. ៧៣៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៧១៥/៧៨៦

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំនួន ០២ រូប ដោយមិនយកប្រាក់បៀវត្ស ដូចខាងក្រោម :

១-លោកជំទាវ **ខួន មករា** ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២-ឯកឧត្តម **ម៉ី បញ្ញាសិទ្ធ** ជាទីប្រឹក្សា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៨២៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ៧ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

៣៧. ១៥០៧. ៨០០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៥*

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៥/៧៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានៈឯកឧត្តមឧត្តមសេនីយ៍ទោ **សាយ បាន** អត្តលេខ ៧៥៩៨៤ ជំនួយការ**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.១៥០៧.៨០១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៥

លេខៈ ៥៦១៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ ៨ ឆ្នាំ២០១៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ៖ ១០៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាផ្នែកអប់រំ ពីជំពូក ៦០ (ការទិញ) មកជំពូក ៦១ (សេវាកម្ម) ចំនួន ៦៦ ០០០ ០០០ រៀល (ហុកសិបប្រាំមួយលានរៀលគត់) និងផ្នែកយុវជន និងកីឡា ពីជំពូក ៦៥ (ឧបត្ថម្ភធន) មកជំពូក ៦២ (អត្ថប្រយោជន៍សង្គម) ចំនួន ១២ ០០០ ០០០ រៀល ជូនក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥។

**មាត្រា២.**

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥។

**មាត្រា៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧ.ម ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១០៤ អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពីការផ្ទេរឥណទានថវិកា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៣៦ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាពីជំពូក៦០(ការទិញ) ចំនួន ៦១៦ ២១៦ ០០០រៀល មកជំពូក៦១ (សេវាកម្ម) ចំនួន៦១៦ ២១៦ ០០០រៀល ជូនក្រសួងរ៉ែ និង ថាមពល សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែងរបស់ក្រសួងរ៉ែ និង ថាមពលសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ៧ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** :..១០៥...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៣៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញប្រកាសលេខ១៩០៤ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាកម្មវិធីថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន៣០ ០០០ ០០០រៀល (សាមសិបលានរៀលគត់) ពីជំពូក៦០(ការទិញ) មកជំពូក៦១ (សេវាកម្ម) ជូនមន្ទីរសុខាភិបាលខេត្តកែប សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកទាំងនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែង របស់មន្ទីរសុខាភិបាលខេត្តកែប សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីតួនាទី ភារកិច្ច របៀបរបបធ្វើការងារ និងរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងនាយកដ្ឋាន ព្រមទាំងលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ចំណុះ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារដឹកនាំរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ក្នុងនាមជាជំនួយការ គ.ជ.ប ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីជួយ គ.ជ.ប ក្នុងការរៀបចំ ចាត់ចែង និងគ្រប់គ្រងការងារបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ដោយអនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប និងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តការងាររបស់អគ្គលេខាធិការដ្ឋាន និងនាយកដ្ឋាន ព្រមទាំងលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ចំណុះអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប។

## ជំពូកទី២
## តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប

**មាត្រា៤ .-**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានតួនាទីធ្វើជាជំនួយការជូន គ.ជ.ប ក្នុងការរៀបចំ ចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់។

**មាត្រា៥ .-**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានភារកិច្ចដូចតទៅ៖

ក- អនុវត្តច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត បទបញ្ជាផ្ទៃក្នុង សេចក្តីសម្រេច និងសេចក្តីណែនាំនានារបស់ គ.ជ.ប។

ខ- លើកសំណើជូន គ.ជ.ប ពិនិត្យ សម្រេចអំពី៖

- តម្រូវការនៃធនធានមនុស្ស
- ផែនការមេចុះឈ្មោះអ្នកបោះឆ្នោត ធ្វើបញ្ជីបោះឆ្នោត និងបច្ចុប្បន្នភាពនៃបញ្ជីបោះឆ្នោត ផែនការសម្រាប់ការបោះឆ្នោត និងប្រតិទិនសម្រាប់ការបោះឆ្នោត
- ផែនការប្រតិបត្តិការ
- ផែនការគ្រប់គ្រង និងចាត់ចែងថវិកា
- គម្រោងថវិកាប្រចាំឆ្នាំ និងថវិកាសម្រាប់ការបោះឆ្នោត
- ផែនការបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត
- ផែនការផ្សព្វផ្សាយអប់រំសាធារណជន
- ផែនការផ្សព្វផ្សាយច្បាប់ ផែនការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ផែនការចុះឈ្មោះតំណាង ឬភ្នាក់ងារគណបក្សនយោបាយ ផែនការទទួលពាក្យបណ្តឹង និងការសហការចាត់ចែងការងារសន្តិសុខបោះឆ្នោត
- ផែនការសវនកម្ម
- របាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍អំពីដំណើរការបោះឆ្នោត

គ- ទទួលរ៉ាប់រងនូវកិច្ចការរដ្ឋបាល និងសេវាកម្មនានាជូន គ.ជ.ប ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅ គ.ជ.ប។

ឃ- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពី គ.ជ.ប។

## ជំពូកទី៣
## រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប

**មាត្រា៦ ._**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានរចនាសម្ព័ន្ធដូចតទៅ៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានប្រតិបត្តិការ
- នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត
- នាយកដ្ឋានហិរញ្ញវត្ថុ
- នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត
- នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- លេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប)។

**មាត្រា៧ .-**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ដឹកនាំដោយអគ្គលេខាធិការ១ (មួយ) រូប មានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ មានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុរដ្ឋលេខាធិការ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធាន គ.ជ.ប បន្ទាប់ពីបានយោបល់យល់ស្របតាមសំឡេងភាគច្រើនដាច់ខាតនៃសមាសភាព គ.ជ.ប ទាំងមូល។

**មាត្រា៨ .-**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានលេខាធិការដ្ឋានមួយជាជំនួយការ សម្រាប់ជួយការងាររបស់អគ្គលេខាធិការ និងអគ្គលេខាធិការរង។ ប្រធានលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

**មាត្រា៩ .-**

អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រី បុគ្គលិកទាំងអស់ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះ គ.ជ.ប។

**មាត្រា១០ .-**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានត្រាសម្រាប់ប្រើប្រាស់ក្នុងការបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និង លធ.ខប ចំណុះអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប

**មាត្រា១១ .-**

នាយកដ្ឋានរដ្ឋបាល មានតួនាទីលើការងារគ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក និងចាត់ចែងឯកសារ ការរៀបចំកិច្ចប្រជុំ សន្និបាត សិក្ខាសាលា ការធ្វើរបាយការណ៍នានារបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប។

នាយកដ្ឋានរដ្ឋបាល មានភារកិច្ចដូចតទៅ៖

- ចាត់ចែងការងាររដ្ឋបាលទូទៅនៃ គ.ជ.ប
- លើកគម្រោងអំពីតម្រូវការនៃធនធានមនុស្ស
- រៀបចំការជ្រើសរើស និងគ្រប់គ្រងមន្ត្រីរាជការ

- លើកគម្រោង និងផ្គត់ផ្គង់សម្ភារបរិក្ខារការិយាល័យសម្រាប់ គ.ជ.ប ប្រចាំឆ្នាំ ក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងក្នុងពេលបោះឆ្នោត
- ថែទាំ និងគ្រប់គ្រងអគារ និងទ្រព្យសម្បត្តិ សម្ភារបរិក្ខាររបស់ គ.ជ.ប
- ប្រមូលសរុបរបាយការណ៍សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ប្រមូលសរុប និងធ្វើសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- រក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ទីស្តីការ គ.ជ.ប
- សហការជាមួយនាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតអំពីការបណ្តុះបណ្តាលការងាររដ្ឋបាលដល់មន្ត្រីរាជការ
- សហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុអំពីការងារសារពើភ័ណ្ឌ
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា១២ ._**

នាយកដ្ឋានប្រតិបត្តិការ មានតួនាទីលើការងាររៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងចាត់ចែងដំណើរនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រមូលសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។

នាយកដ្ឋានប្រតិបត្តិការ មានភារកិច្ចដូចតទៅៈ

- រៀបចំផែនការការងារ និងប្រតិទិននៃកិច្ចប្រតិបត្តិការបោះឆ្នោត
- ប៉ាន់ស្មានស្ថិតិប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត និងកំណត់ចំនួនទីតាំងការិយាល័យបោះឆ្នោត
- ចាត់ចែងលើកគម្រោងផែនការ ថវិកាដើម្បីផ្គត់ផ្គង់សម្ភារឯកសារ និងសេវាផ្សេងៗសម្រាប់បម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ធ្វើគំរូទម្រង់បែបបទសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ចាត់ចែងលើកគម្រោងផែនការ និងតម្រូវការមន្ត្រីចុះឈ្មោះបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងផ្តល់ឯកសារនេះ ជូននាយកដ្ឋានរដ្ឋបាល
- ចាត់ចែងគ្រប់គ្រងឯកសារ សម្ភារបរិក្ខារនៅឃ្លាំង គ.ជ.ប
- ចាត់ចែង និងសម្របសម្រួលរាល់កិច្ចប្រតិបត្តិការនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត

- តាមដានសរុបព័ត៌មានដែលទទួលបានតាមវិទ្យុទាក់ទង ទូរស័ព្ទ ទូរសារ អំពីបញ្ហាពាក់ព័ន្ធនឹងដំណើរការនៃការបោះឆ្នោត និងរាយការណ៍ជាប្រចាំជូនអគ្គលេខាធិការ និង គ.ជ.ប
- ត្រួតពិនិត្យគុណភាពសម្ភារ ឯកសារបោះឆ្នោត ការវេចខ្ចប់ និងការដឹកជញ្ជូនសម្ភារបោះឆ្នោតឱ្យចំគោលដៅ ប្រកបដោយសន្តិសុខ និងសុវត្ថិភាព
- ចាត់ចែងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត និងបញ្ចូលទិន្នន័យលទ្ធផលក្នុងកុំព្យូទ័រ និងគ្រប់គ្រងរក្សាកំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា១៣ .-**

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត មានតួនាទីលើការងារបច្ចេកទេសចុះឈ្មោះបោះឆ្នោត ការទទួល ការបញ្ជូន និងគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោតក្នុងប្រព័ន្ធកុំព្យូទ័រ ព្រមទាំងរក្សាទុកនូវឯកសារពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោត ប្រកបដោយសុវត្ថិភាព។

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងថែរក្សាកម្មវិធីបញ្ចូលទិន្នន័យ និងសម្ភារបរិក្ខារកុំព្យូទ័រសម្រាប់ការចុះឈ្មោះបោះឆ្នោត
- គ្រប់គ្រងចាត់ចែងទទួលទិន្នន័យបញ្ជូនពីឃុំ សង្កាត់តាមអនឡាញ (Online) និងឯកសារអ្នកចុះឈ្មោះបោះឆ្នោត
- គ្រប់គ្រង ផ្ទៀងផ្ទាត់ទិន្នន័យពីឃុំ សង្កាត់ និងសុំយោបល់សម្រេចពី គ.ជ.ប ក្នុងករណីពិនិត្យឃើញមានភាពមិនត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោត
- រៀបចំចាត់ចែងផលិតបញ្ជីបោះឆ្នោតដំបូង
- គ្រប់គ្រង និងផលិតបញ្ជីបោះឆ្នោតផ្លូវការ និងបណ្ណព័ត៌មានអ្នកបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោតនីមួយៗ និងការបោះឆ្នោតផ្សេងៗទៀត តាមការកំណត់ដោយច្បាប់
- ផ្តល់របាយការណ៍គ្រប់គ្រាន់ពាក់ព័ន្ធនឹងចំនួនអ្នកបោះឆ្នោត (ចុះឈ្មោះថ្មី លុប កែតម្រូវទិន្នន័យ ស្ទួន ឈ្មោះ ភេទ អាយុ) ជូន គ.ជ.ប ដើម្បីពិនិត្យ និងសម្រេច
- ផលិត CD ផ្ទុកបញ្ជីបោះឆ្នោតជាទម្រង់ Pdf ជូន លធ.ខប និងទុកជាឯកសារ
- បង្ហោះបញ្ជីបោះឆ្នោតផ្លូវការតាមគេហទំព័ររបស់ គ.ជ.ប
- សហការជាមួយនាយកដ្ឋានប្រតិបត្តិការអំពីការរៀបចំបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងស្ថិតិតួលេខអ្នកបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា១៤ ._**

នាយកដ្ឋានហិរញ្ញវត្ថុ មានតួនាទីលើការងារហិរញ្ញវត្ថុរបស់ គ.ជ.ប។

នាយកដ្ឋានហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងសកម្មភាពហិរញ្ញវត្ថុ និងបន្ទុកគណនីរបស់ គ.ជ.ប
- គ្រប់គ្រងចំណូល-ចំណាយថវិការបស់ គ.ជ.ប ទាំងមូល
- រៀបចំគ្រប់គ្រង ការបែងចែក និងការត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុនៃ គ.ជ.ប
- គ្រប់គ្រង ត្រួតពិនិត្យទ្រព្យសម្បត្តិ និងចុះបញ្ជីសារពើភ័ណ្ឌរបស់ គ.ជ.ប
- ធ្វើគម្រោងផែនការថវិការបស់ គ.ជ.ប
- រៀបចំគ្រប់គ្រងថវិកា បែងចែកថវិកា ត្រួតពិនិត្យថវិកា និងបញ្ជិកាគណនេយ្យនៃ គ.ជ.ប ទាំងមូល និងនៅគ្រប់លំដាប់ថ្នាក់
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបញ្ជិកាគណនេយ្យនៃ គ.ជ.ប ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ត្រួតពិនិត្យសក្ខីបត្រចំណាយ និងឯកសារទូទាត់ថវិការបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត
- ត្រួតពិនិត្យការអនុវត្តនីតិវិធីនៃលទ្ធកម្មសាធារណៈរបស់ គ.ជ.ប
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា១៥ ._**

នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត មានតួនាទីលើការងារបណ្តុះបណ្តាលមន្ត្រីរាជការនៃ គ.ជ.ប និងភាគីពាក់ព័ន្ធ និងអប់រំអ្នកបោះឆ្នោត។

នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត មានភារកិច្ចដូចតទៅ៖

- លើកគម្រោងផែនការ និងបង្កើតកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីរាជការនៃ គ.ជ.ប មន្ត្រីចុះឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងគ្រប់ភាគីពាក់ព័ន្ធ
- ចងក្រង និងផលិតឯកសារបណ្តុះបណ្តាលសម្រាប់ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- លើកគម្រោងផែនការ កម្មវិធីអប់រំអ្នកបោះឆ្នោត និងសិក្សាស្រាវជ្រាវរកខ្លឹមសារសំខាន់ៗ ដើម្បីផលិតសម្ភារ និងរូបភាពសម្រាប់អប់រំអ្នកបោះឆ្នោតទៅតាមដំណាក់កាលនៃការបោះឆ្នោត
- ប្រមូលសរុបវាយតម្លៃអំពីកម្រិតយល់ដឹងរបស់អ្នកបោះឆ្នោតជូន គ.ជ.ប
- សហការត្រួតពិនិត្យ និងផ្តល់យោបល់រាល់ខ្លឹមសារ និងរូបភាពផ្សេងៗសម្រាប់អប់រំអ្នកបោះឆ្នោតដែលស្នើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា១៦ ..**

នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ មានតួនាទីលើការងារទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ ទាក់ទងនឹងកិច្ចការបោះឆ្នោត និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតជូនសាធារណជន។

នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចតទៅ៖

- ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការងារបោះឆ្នោតតាមគ្រប់មធ្យោបាយផ្សេងៗ
- រៀបចំសៀវភៅណែនាំស្តីពីការឃោសនាបោះឆ្នោត សេចក្តីថ្លែងការណ៍ សេចក្តីប្រកាសព័ត៌មាន សេចក្តីជូនដំណឹង និងគោលការណ៍ផ្សេងៗ
- រៀបចំ និងផលិតឯកសារផ្សព្វផ្សាយអប់រំសាធារណជន
- ផ្សព្វផ្សាយលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ និងលទ្ធផលនៃការបោះឆ្នោត
- តាមដានសកម្មភាពឃោសនារបស់គណបក្សនយោបាយ ការផ្សព្វផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងតាមប្រព័ន្ធផ្សព្វផ្សាយសង្គមពាក់ព័ន្ធនឹងការបោះឆ្នោត
- រៀបចំសន្និសីទសារព័ត៌មាន និងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ថតសកម្មភាពវីដេអូ រូបភាព សំឡេង និងធ្វើកំណត់ហេតុប្រជុំ-សន្និសីទ
- ចងក្រងឯកសារវីដេអូ រូបភាព សំឡេង CD Data និងឯកសារផ្លូវការផ្សេងៗ ជាសៀវភៅ
- គ្រប់គ្រងគេហទំព័រ (Website) និងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ គ.ជ.ប
- ទទួលពាក្យ និងរៀបចំផ្តល់ប័ណ្ណសម្គាល់ខ្លួនសម្រាប់អ្នកសារព័ត៌មានជាតិ-អន្តរជាតិ ដែលចូលរួមយកព័ត៌មានបោះឆ្នោត
- យកព័ត៌មានតាមរាជធានី ខេត្ត និងព័ត៌មានក្នុងកម្មវិធីផ្សេងៗរបស់ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត តាមការចាត់តាំងរបស់ គ.ជ.ប
- ទំនាក់ទំនង និងផ្លាស់ប្តូរព័ត៌មានជាមួយស្ថាប័នជាតិ-អន្តរជាតិអំពីការបោះឆ្នោត
- បកប្រែឯកសារពីភាសាខ្មែរទៅភាសាអង់គ្លេស និងពីភាសាអង់គ្លេសមកជាភាសាខ្មែរ ដើម្បីធ្វើការផ្សព្វផ្សាយ
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា១៧ ._**

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម មានតួនាទីសិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ ចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោត និងទទួលពាក្យបណ្ដឹងពាក់ព័ន្ធនឹងការងារបោះឆ្នោត ព្រមទាំងសហការលើផ្នែកសន្តិសុខ សុវត្ថិភាពបោះឆ្នោត។

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម មានភារកិច្ចដូចតទៅ៖

- សិក្សា ស្រាវជ្រាវ និងជូនយោបល់ខាងផ្នែកច្បាប់ដល់ គ.ជ.ប
- ចងក្រង និងបោះពុម្ពឯកសារច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ច្បាប់បោះឆ្នោត និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងការបោះឆ្នោត
- រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ និងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- រៀបចំសៀវភៅណែនាំនីតិវិធីសម្រាប់ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងសម្រាប់ការបោះឆ្នោត សេចក្ដីព្រាងក្រមសីលធម៌ និងឯកសារណែនាំផ្សេងៗទាក់ទងនឹងការងារអ្នកសង្កេតការណ៍ បេក្ខជនឈរឈ្មោះបោះឆ្នោត និងគណបក្សនយោបាយ
- អនុវត្តនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង
- អនុវត្តនីតិវិធីនៃការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត
- អនុវត្តនីតិវិធីនៃការផ្លាស់ប្ដូរសមាជិកព្រឹទ្ធសភា និងតំណាងរាស្ត្ររបស់គណបក្សនយោបាយ តាមសំណើសុំ
- ចាត់ចែងការងារចុះបញ្ជីបេក្ខជនបម្រុងបន្ថែមនៃសមាជិកព្រឹទ្ធសភា តំណាងរាស្ត្រ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់
- ចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងតំណាង ឬភ្នាក់ងារគណបក្សនយោបាយក្នុងការបោះឆ្នោត
- សហការលើកិច្ចការសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈសម្រាប់ការបោះឆ្នោត
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា១៨ ._**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានតួនាទីលើការងារសវនកម្មលើនាយកដ្ឋាន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការសវនកម្មប្រចាំឆ្នាំជូនប្រធាន គ.ជ.ប ពិនិត្យ និងសម្រេច
- ត្រួតពិនិត្យកម្មវិធី និងសកម្មភាពកិច្ចសហប្រតិបត្តិការរបស់អង្គភាពនានាក្នុងគោលដៅអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍ នីតិវិធី និងបែបបទការងាររបស់ គ.ជ.ប
- ត្រួតពិនិត្យដើម្បីឱ្យមានការគោរពដាច់ខាតនូវបទប្បញ្ញត្តិផ្សេងៗជាធរមានពាក់ព័ន្ធ និងប្រតិបត្តិការហិរញ្ញវត្ថុ គណនេយ្យ រដ្ឋបាល បុគ្គលិក និងបច្ចេកទេសរបស់ គ.ជ.ប
- កំណត់វិធានការកែលម្អលើកិច្ចប្រតិបត្តិការ និងលើកអនុសាសន៍ដល់អង្គភាពពាក់ព័ន្ធ
- ធ្វើរបាយការណ៍ជូន គ.ជ.ប ដោយមានសេចក្តីសន្និដ្ឋាន អនុសាសន៍ និងដំណោះស្រាយ កែលម្អសមស្រប ហើយត្រូវផ្ញើរបាយការណ៍ចតចម្លងទៅអាជ្ញាធរសវនកម្មជាតិ
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា១៩ .-**

លេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត នៅក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយទៀត ត្រូវបានហៅថា លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) មានភារកិច្ចដូចតទៅៈ

- ទំនាក់ទំនងជាមួយអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ទទួលបញ្ជីឈ្មោះប្រជាពលរដ្ឋដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដែលបានផ្លាស់លំនៅដ្ឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេងពីស្មៀនឃុំ សង្កាត់ រៀងរាល់ ២ (ពីរ) ខែម្តង។ ក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវសហការជាមួយក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗដើម្បីលុបឈ្មោះប្រជាពលរដ្ឋទាំងនោះចេញពីបញ្ជីបោះឆ្នោត
- ទទួលបញ្ជីឈ្មោះប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះពីមុនមក ដែលទើបដល់អាយុត្រូវបោះឆ្នោត ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មីពីស្មៀនឃុំ សង្កាត់ រៀងរាល់២ (ពីរ) ខែម្តង
- ពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីចាត់ឱ្យក្រុមចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះចល័តស្របតាមបទបញ្ជា និងនីតិវិធី
- សហការជាមួយឃុំ សង្កាត់ ធ្វើការប៉ាន់ស្មានចំនួនប្រជាជនក្នុងឃុំ សង្កាត់ ចំនួនពលរដ្ឋអាយុ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ
- រាយការណ៍ជូន គ.ជ.ប អំពីដំណើរការចុះឈ្មោះបោះឆ្នោត
- ទទួល ប្រគល់សម្ភារបរិក្ខារនៃ គ.ជ.ប និងឃុំ សង្កាត់
- ជំនួយការឱ្យ គ.ជ.ប ក្នុងការជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ

- ជំនួយការឱ្យ គ.ជ.ប ក្នុងការដោះស្រាយបញ្ហានានាដែលអាចកើតមាននៅក្នុងរាជធានី ខេត្តនីមួយៗ
- ជំនួយការឱ្យគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ក្នុងដំណាក់កាលបោះឆ្នោត
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**មាត្រា២០ .-**

នាយកដ្ឋាននីមួយៗចំណុះអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ដឹកនាំដោយប្រធាន១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

នាយកដ្ឋាននីមួយៗមានការិយាល័យមួយចំនួនចំណុះតាមការចាំបាច់។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន១ (មួយ) រូប និងមានអនុប្រធានការិយាល័យមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា២១ .-**

ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងអង្គភាពផ្សេងៗទៀត ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ គ.ជ.ប តាមសំណើរបស់អគ្គលេខាធិការនៃ គ.ជ.ប ស្របតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃ គ.ជ.ប។

**មាត្រា២២ .-**

ការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងភារកិច្ចរបស់ការិយាល័យ និងអង្គភាពផ្សេងទៀតចំណុះនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

**មាត្រា២៣ .-**

អង្គការលេខនៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា២៤ .-**

នៅក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងក្នុងពេលបោះឆ្នោត មន្ត្រីរាជការដែលត្រូវបានជ្រើសរើសជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល។

**មាត្រា២៥ .-**

មន្ត្រីរាជការនៃ គ.ជ.ប មានឯកសណ្ឋានសម្រាប់បម្រើការងារ។ ឯកសណ្ឋានត្រូវកំណត់ដោយ គ.ជ.ប។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា២៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៧ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវសហការជាមួយ គ.ជ.ប ដើម្បីអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ស៊ិក ប៊ុនហុក**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...១៨៧.....អនក្រ.បក
ចុះថ្ងៃទី.១០.ខែកក្កដាឆ្នាំ២០១៥

# អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន
# នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើត និងដាក់ឲ្យដំណើរការទីភ្នាក់ងារជាតិមុខរបរ និងការងារ
- យោងសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-**

ប្រគល់ភារកិច្ចជូនលោកស្រី **អ៊ូច ជាច័ន្ទមល្លិកា** ជាទីប្រឹក្សាទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៨០៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

### សម្រេច

**មាត្រា១.**_បំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីអង្គការ JMAS ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | សយ | ថៃលី | Planning and Coordination Officer |
| ២-លោក | អុំ | ទិដ្ឋ | Interpreter , Assistant TA & Driver |
| ៣-លោក | ទ៉ាត | ប្រាំង | Interpreter and Assistant |
| ៤-លោក | ហៀង | សុខហេង | Interpreter and Assistant |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧៥៨..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ សេនា ចំនួន០១គ្រឿង ជូនលោក **ហ៊ោ ឪណា** មន្ត្រីកម្មវិធីសុខភាពនៃអង្គការ KOICA Cambodia ដែលមានស្នាដៃល្អជួយជ្រោមជ្រែងក្នុងការកសាងអគារមជ្ឈមណ្ឌលចក្ខុរោគមិត្តភាពកម្ពុជា-កូរ៉េ ស្ថិតនៅក្នុងបរិវេណមន្ទីរពេទ្យព្រះអង្គឌួង ព្រមទាំងបំពាក់សម្ភារបរិក្ខារបច្ចេកទេស និងគ្រឿងសង្ហារឹម កន្លងមកសម្រេចបានលទ្ធផលល្អប្រសើរ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
| ១៣២ | - ដៃបាញ់ប្រេងចំនួន១ (តាមស្ថានីយ) | ៤០ ០០០ | ២០ ០០០ | ចេញភ្លាម | ១ឆ្នាំ |
| ១៣៣ | - ធុងហ្គាស (អប្បបរមា ៧គីឡូក្រាម) | ឥតគិតថ្លៃ | | ចេញភ្លាម | ១ឆ្នាំ |
| ១៣៤ | - ធុងហ្គាស (១៥ គីឡូក្រាម) | ឥតគិតថ្លៃ | | ចេញភ្លាម | ១ឆ្នាំ |
| ១៣៥ | - ធុងហ្គាស (លើសពី១៥ គីឡូក្រាម) | ឥតគិតថ្លៃ | | ចេញភ្លាម | ១ឆ្នាំ |
| ១៣៦ | - ដៃវែប្អូមប្រេងចំនួន១ | ១០ ០០០ | ៨ ០០០ | ចេញភ្លាម | ១ឆ្នាំ |
| ១៣៧ | - ឧបករណ៍បែងចែក (flow meter) ប្រេងឥន្ធនៈ និងឧស្ម័ន | ២០០ ០០០ | ១៦០ ០០០ | ចេញភ្លាម | ១ឆ្នាំ |
| | ឃ.៤- កុងទ័រទឹក (ក្រុមហ៊ុនចែកចាយ ឬអ្នកផ្គត់ផ្គង់កុងទ័រទឹក) | | | | |
| ១៣៨ | - ឧបករណ៍ដែលមានអង្កត់ផ្ចិតតូចជាង ឬស្មើ ១៦មីល្លីម៉ែត្រ | ៥ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៣៩ | - ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ១៦មីល្លីម៉ែត្រ ដល់ ៣២មីល្លីម៉ែត្រ | ១០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៤០ | - ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ៣២មីល្លីម៉ែត្រ ដល់ ៦០មីល្លីម៉ែត្រ | ១៥ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៤១ | - ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ៦០មីល្លីម៉ែត្រ ដល់ ១០០មីល្លីម៉ែត្រ | ២០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៤២ | - ឧបករណ៍ដែលមានអង្កត់ផ្ចិតលើសពី ១០០មីល្លីម៉ែត្រឡើង | ៣០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| | ឃ.៥- ឧបករណ៍វាស់ប្រវែង | | | | |
| ១៤៣ | - មីក្រូម៉ែត្រ | ៤០ ០០០ | ៣០ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ១៤៤ | - កុងទ័រតាក់ស៊ី | ៥០ ០០០ | ៤០ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ១៤៥ | - ប្រវែងតូចជាង ឬស្មើ ១០ម៉ែត្រ(ប្រើក្នុងឧស្សាហកម្ម) | ៥០ ០០០ | ៣០ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ១៤៦ | - ប្រវែងលើសពី ១០ម៉ែត្រឡើង | ៦០ ០០០ | ៤០ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| | ឃ.៦- ឧបករណ៍វាស់សីតុណ្ហភាព | | | | ១ឆ្នាំ |
| ១៤៧ | - សីតុណ្ហភាពតូចជាង ឬស្មើ ៥០អង្សាសេ (ប្រើក្នុងអាជីវកម្ម និងសេវាកម្មទូទៅ) | ៣ ០០០ | ២ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ១៤៨ | - សីតុណ្ហភាពចាប់ពី -៥អង្សាសេ ដល់ ១០៥អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ១០០ ០០០ | ៨០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១៤៩ | - សីតុណ្ហភាពចាប់ពី -៥អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ១៥០ ០០០ | ១២០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១៥០ | - សីតុណ្ហភាពចាប់ពី -៣០អង្សាសេ ដល់ ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ២៥០ ០០០ | ១៥០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១៥១ | - សីតុណ្ហភាពលើសពី ២០០អង្សាសេ (ប្រើក្នុងឧស្សាហកម្ម) | ៤០០ ០០០ | ៣៥០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | | ត្រួតពិនិត្យលើកដំបូង (ឧបករណ៍ថ្មី និងប្រើប្រាស់) | ត្រួតពិនិត្យលើកបន្ទាប់ (ឧបករណ៍ប្រើប្រាស់) | | |
| | ឃ.៧- ឧបករណ៍វាស់ថាមពល | | | | |
| | + ឧបករណ៍វាស់អគ្គិសនី (ជាតម្រូវការរបស់អតិថិជន) | | | | |
| ១៥២ | - វ៉ុលម៉ែត្រ(V) | ៤០ ០០០ | ៣០ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| ១៥៣ | - អំពែម៉ែត្រ អូមម៉ែត្រ វ៉ាត់ | ៥០ ០០០ | ៤០ ០០០ | ៣ថ្ងៃ | ១ឆ្នាំ |
| | + កុងទ័រអគ្គិសនីម៉ូណូហ្វា (ក្រុមហ៊ុនចែកចាយ ឬអ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | | | | |
| ១៥៤ | - ចាប់ពី ៥ ដល់ ១០អំពែ | ៥ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៥៥ | - លើសពី ១០អំពែ ដល់ ២០អំពែ | ១០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៥៦ | - លើសពី ២០អំពែ ដល់ ៣០អំពែ | ១៥ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៥៧ | - លើសពី ៣០អំពែ ដល់ ៥០អំពែ | ២០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៥៨ | - លើសពី ៥០អំពែ ដល់ ១០០អំពែ | ៦០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៥៩ | - លើសពី ១០០អំពែឡើង | ៨០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| | + កុងទ័រអគ្គិសនីទ្រីហ្វា (ក្រុមហ៊ុនចែកចាយ ឬអ្នកផ្គត់ផ្គង់កុងទ័រអគ្គិសនី) | | | | |
| ១៦០ | - ចាប់ពី ៥ ដល់ ១០អំពែ | ១០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦១ | - លើសពី ១០អំពែ ដល់ ២០អំពែ | ២០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦២ | - លើសពី ២០អំពែ ដល់ ៣០អំពែ | ៦០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦៣ | - លើសពី ៣០អំពែ ដល់ ៥០អំពែ | ៨០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦៤ | - លើសពី ៥០អំពែ ដល់ ១០០អំពែ | ១២០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦៥ | - លើសពី ១០០អំពែឡើង | ៣០០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| | ឃ.៨- ឧបករណ៍វាស់សម្ពាធ (ប្រើប្រាស់នៅរោងចក្រ សហគ្រាស) | | | | |
| ១៦៦ | - សម្ពាធតូចជាង ឬស្មើ ១០គីឡូប៉ាស្កាល់ | ១៥ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦៧ | - សម្ពាធលើសពី ១០គីឡូប៉ាស្កាល់ ដល់ ៣០គីឡូប៉ាស្កាល់ | ២០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦៨ | - សម្ពាធលើសពី ៣០គីឡូប៉ាស្កាល់ ដល់ ១៥០គីឡូប៉ាស្កាល់ | ២៥ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៦៩ | - សម្ពាធលើសពី ១៥០គីឡូប៉ាស្កាល់ឡើង | ៣០ ០០០ | | ៣ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៧០ | ឃ.៩- ម៉ាស៊ីនតេស្តពណ៌ក្រណាត់ (ប្រើប្រាស់នៅរោងចក្រ សហគ្រាស) | ២០០ ០០០ | | ចេញភ្លាម | |
| ១៧១ | ឃ.១០- ម៉ាស៊ីនវាស់លោហៈធាតុ (ប្រើប្រាស់នៅរោងចក្រ សហគ្រាស) | ២០០ ០០០ | | ចេញភ្លាម | |

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | | ត្រួតពិនិត្យលើកដំបូង (ឧបករណ៍ថ្មី និងប្រើប្រាស់) | ត្រួតពិនិត្យលើកបន្ទាប់ (ឧបករណ៍ប្រើប្រាស់) | | |
| ង. ត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងផ្លាកសញ្ញាមាត្រាសាស្ត្រលើទំនិញផលិត និងទំនិញវេចខ្ចប់ | | | | | |
| | ង.១- ទំនិញផលិត | | | | |
| | + វាយនភ័ណ្ឌ (មួយមុខផលិតផល) | | | | |
| ១៧២ | - សំលៀកបំពាក់ | ២០ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |
| ១៧៣ | - កំរាលព្រំ | ២០ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |
| ១៧៤ | សម្ភារសំណង់ (មួយមុខផលិតផល) | ៤០ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| ១៧៥ | បរិក្ខារអគ្គិសនី អេឡិកត្រូនិច និងអុបទិក (មួយមុខផលិតផល) | ៤០ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| | ង.២- ទំនិញវេចខ្ចប់ | | | | |
| | + ជាតុស្ងួន ផលិតផលចំណីអាហារ និងវត្ថុរាវគ្រប់ប្រភេទ (មួយមុខផលិតផល) | | | | |
| ១៧៦ | - តិចជាង ឬស្មើ ៥គីឡូក្រាម ឬលីត្រ | ២០ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| ១៧៧ | - លើសពី ៥គីឡូក្រាម ឬលីត្រ ដល់ ១០គីឡូក្រាម ឬលីត្រ | ២៥ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| ១៧៨ | - លើសពី ១០គីឡូក្រាម ឬលីត្រ ដល់ ២០គីឡូក្រាម ឬលីត្រ | ៣០ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| ១៧៩ | - លើសពី ២០គីឡូក្រាម ឬលីត្រ ដល់ ៣០គីឡូក្រាម ឬលីត្រ | ៣៥ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| ១៨០ | - លើសពី ៣០គីឡូក្រាម ឬលីត្រ ដល់ ៥០គីឡូក្រាម ឬលីត្រ | ៤០ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| ១៨១ | - លើសពី ៥០គីឡូក្រាម ឬលីត្រ | ៥០ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| ១៨២ | - សំណើមក្នុងគ្រាប់ធញ្ញជាតិ | ២០ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| ១៨៣ | - ភាពក្លីលើគ្រាប់ធញ្ញជាតិ | ៥០ ០០០ | | ៣ថ្ងៃ | ១ឆ្នាំ |
| | + ផលិតផលឱសថគ្រប់ប្រភេទ (មួយមុខផលិតផល) | | | | |
| ១៨៤ | - ប្រភេទគ្រាប់ | ១២ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |
| ១៨៥ | - ប្រភេទអំពូល | ១៥ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |
| ១៨៦ | - ប្រភេទទឹកសេរ៉ូម | ២០ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |
| ១៨៧ | ផលិតផលថ្នាំជក់ និងក្រដាស (មួយមុខផលិតផល) | ២០ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |
| | + ផលិតផលគីមី | | | | |
| ១៨៨ | - សាប៊ូដុំ ម្សៅសាប៊ូ គ្រឿងសំអាត ប៉ូលាគ្រឿងក្រអូប ឬគ្រឿងសំអាង | ២០ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |
| ១៨៩ | - ថ្នាំសម្លាប់សត្វល្អិត ឬជីគីមីកសិកម្ម | ៣០ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |
| ១៩០ | - ថ្នាំលាបពណ៌ វ៉ែរនី ថ្នាំទ្រនាប់ ទឹកថ្នាំបោះពុម្ព ឬម៉ាស្ទិក | ៤០ ០០០ | | ២ថ្ងៃ | ១ឆ្នាំ |

តារាងឧបសម្ព័ន្ធទី២ ភ្ជាប់នឹងប្រកាសរួមលេខ[illegible]..ឧសហក ចុះថ្ងៃទី...០៩..... ខែ.កក្កដា... ឆ្នាំ២០១៥

ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ប្រភេទបទល្មើស និងការពិន័យជាប្រាក់ដែលស្ថិតក្រោមសមត្ថកិច្ចបង្ក្រាបបទល្មើសដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម

| ល.រ | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| **ក. បទល្មើសដែលចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម** | | |
| 01 | ក្នុងករណីបង្កើតសិប្បកម្ម ដែលតម្រូវឱ្យស្នើចុះបញ្ជី ដោយពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងពុំបានធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ដែលខ្លួនបានបោះទីតាំងក្នុងរយៈពេល ០៧ថ្ងៃ ក្រោយថ្ងៃដំណើរការ (មាត្រា៤៣) | ពី 500,000 ទៅ 2,500,000 |
| 02 | ក្នុងករណីបង្កើតប្រភេទសិប្បកម្ម ដែលចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយគ្មានការអនុញ្ញាត (មាត្រា៤៣) | ពី 1,000,000 ទៅ 5,000,000 |
| 03 | ក្នុងករណីពង្រីក ឬបង្កើតសាខា ឬផ្លាស់ប្តូរទីតាំងរោងចក្រពុំមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |
| 04 | ក្នុងករណីប្តូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មីពុំបានធ្វើការសុំទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្មនិង សិប្បកម្ម ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធជាម្ចាស់រោងចក្រថ្មី (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |
| 05 | ក្នុងករណីម្ចាស់រោងចក្រទទួលមរណភាព ឬអសមត្ថភាពតាមផ្លូវច្បាប់ អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត ពុំបានធ្វើពាក្យសុំទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ៤៥ ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណភាព ឬបាត់បង់សមត្ថភាពតាមផ្លូវច្បាប់ (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |
| 06 | ក្នុងករណីម្ចាស់រោងចក្រ ពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេលមួយខែ មុនថ្ងៃ ដែលរោងចក្របញ្ឈប់ដំណើរការជាស្ថាពរ (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |
| 07 | ក្នុងករណីម្ចាស់រោងចក្រ ពុំបានតាំងបង្ហាញប្រកាសបង្កើតរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |

| ល.រ | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| 08 | ក្នុងករណីបាត់បង់ប្រកាសរោងចក្រ ឬ/និងលិខិតអនុញ្ញាតទាំងឡាយ ម្ចាស់រោងចក្រពុំបានធ្វើពាក្យសុំប្រកាស ឬលិខិតជំនួសមួយទៀត មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃបាត់បង់ (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |
| 09 | ក្នុងករណីរោងចក្រ ពុំមានផ្លាកឈ្មោះពុំបានលើកបង្ហាញផ្លាកឈ្មោះរោងចក្រ នៅកន្លែងងាយមើលឃើញខាងមុខរោងចក្រ ហើយផ្លាកឈ្មោះពុំបានសរសេរជាអក្សរខ្មែរ មានទំហំធំជាង និងនៅលើអក្សរផ្សេងៗទៀត (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |
| 10 | ក្នុងករណីផ្លាស់ប្តូរឈ្មោះរោងចក្រ ដោយគ្មានការយល់ព្រមពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |
| 11 | ក្នុងករណីមានឧប្បត្តិហេតុ ឬគ្រោះថ្នាក់នៅក្នុងរោងចក្រ ដែលបណ្តាលឱ្យរោងចក្រផ្អាកដំណើរការទាំងស្រុង លើសពី៧ថ្ងៃ ហើយម្ចាស់រោងចក្រពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ (មាត្រា៤៤) | ពី 2,000,000 ទៅ 10,000,000 |
| 12 | ក្នុងករណីមិនមានប្រព័ន្ធបង្ការអគ្គិភ័យ ដែលរួមមាន ÷<br>- ប្រព័ន្ធប្រកាសភាពអាសន្ន និងមធ្យោបាយសម្រាប់ពន្លត់អគ្គីភ័យ<br>- សញ្ញាប្រយ័ត្នអគ្គិភ័យនៅកន្លែងដែលចាំបាច់<br>- ទ្វារសង្គ្រោះមានយ៉ាងតិចបំផុតចំនួនពីរនៅតាមជាន់នីមួយៗ<br>- ផ្លូវសង្គ្រោះសម្រាប់រថយន្តពន្លត់អគ្គិភ័យ<br>- មធ្យោបាយរំដោះខ្លួនផ្សេងៗទៀត<br>- ប្លង់បំព្រួញសម្រាប់ជម្លៀសខ្លួនពេលមានអាសន្ន (មាត្រា៤៦) | ពី 2,000,000 ទៅ 10,000,000 |
| 13 | ក្នុងករណីម៉ាស៊ីន ឬផ្នែកម៉ាស៊ីនដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដោយថាហេតុមិនមានគម្រប ឬឧបករណ៍ការពារ (មាត្រា៤៦) | ពី 2,000,000 ទៅ 10,000,000 |
| 14 | ក្នុងករណីមិនមានសញ្ញាបង្ហាញប្រាប់ប្រយ័ត្នគ្រោះថ្នាក់ ឬបំរាមនៅកន្លែងដែលមានគ្រោះថ្នាក់ (មាត្រា៤៦) | ពី 2,000,000 ទៅ 10,000,000 |
| 15 | ក្នុងករណីប្រើប្រាស់ជាតិផ្ទុះ គ្រឿងឆេះ ជាតិពុល គីមីគ្រោះថ្នាក់ ឬឧស្ម័នក្នុងផលិតកម្ម មិនបានប្រតិបត្តិតាមលក្ខណៈបច្ចេកទេសដែលធានាបាននូវសុវត្ថិភាព (មាត្រា៤៦) | ពី 2,000,000 ទៅ 10,000,000 |

| ល.រ | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| 16 | ក្នុងករណីឡចំហាយប្រព័ន្ធ ប្រើប្រាស់ចំហាយឧបករណ៍ឬធុងដែលប្រើសំពាធខ្ពស់មិនមានការត្រួតពិនិត្យ និងអនុញ្ញាតពីក្រសួងឧស្សាហកម្មនិងសិប្បកម្ម មុនពេលដំណើការ (មាត្រា៤៦) | ពី 2,000,000 ទៅ 10,000,000 |
| 17 | ក្នុងករណីម្ចាស់រោងចក្រមិនបានផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម (មាត្រា ៤៧) | ពី 10,000,000 ទៅ 50,000,000 |
| 18 | ក្នុងករណី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ផ្អាកសកម្មភាពរោងចក្រទាំងឡាយណា ដែលបានបង្កើតដោយគ្មានច្បាប់អនុញ្ញាត ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយកំណត់ ដើម្បីតម្រូវឱ្យរោងចក្រ ឬអ្នកគ្រប់គ្រងរោងចក្រ ធ្វើការកែតម្រូវកំហុសរបស់ខ្លួនឡើងវិញ (មាត្រា៤៨) | ពី 2,000,000 ទៅ 10,000,000 |
| 19 | ក្នុងករណី ការបង្កើតរោងចក្រពុំមានប្រកាសអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលផ្តោតសំខាន់ទៅលើ ÷<br>-ការរៀបចំទីកន្លែង ឬ/និងការសាងសង់អគារ សម្រាប់ដំណើរការរោងចក្រ<br>-ការសាងសង់អគារ សម្រាប់បំពាក់ម៉ាស៊ីន ដើម្បីដំណើរការរោងចក្រ<br>-ការបំពាក់ម៉ាស៊ីនក្នុងអគារ ទីកន្លែង ឬយានយន្តសម្រាប់ដំណើរការរោងចក្រ<br>-វត្ថុធាតុដើមសម្រាប់ដំណើរការរោងចក្រ (មាត្រា ៤៩) | ពី 10,000,000 ទៅ 50,000,000 |
| 20 | ក្នុងករណី ម្ចាស់រោងចក្រពុំបានជូនដំណឹងមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានមុនរយៈពេល ១៥ថ្ងៃ មុននឹងចាប់ផ្តើមដំណើរការរោងចក្រ (មាត្រា ៤៩) | ពី 10,000,000 ទៅ 50,000,000 |
| 21 | ក្នុងករណី ម្ចាស់រោងចក្រដែលមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពុំបានធ្វើការចុះបញ្ជីរោងចក្រនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងពុំបានផ្តល់ទិន្នន័យ និងរបាយការណ៍ (មាត្រា ៤៩) | ពី 10,000,000 ទៅ 50,000,000 |
| **ខ. បទល្មើសដែលចែងក្នុងច្បាប់ ស្តីពីស្តង់ដារកម្ពុជា** | | |
| 22 | ការប្រើប្រាស់ពាណិជ្ជសញ្ញា ដូចគ្នាទៅនឹងសញ្ញាស្តង់ដារ (មាត្រា ៥០) | ពី 500,000 ទៅ 2,000,000 |
| 23 | ការមិនបានដាក់តាំងអាជ្ញាប័ណ្ណ ឬមិនបានសុំទុតិយតា ឬមិនបានសុំអាជ្ញាប័ណ្ណថ្មី (មាត្រា ៥១) | ពី 500,000 ទៅ 2,000,000 |

| ល.រ | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| 24 | ការមិនបានចុះបញ្ជី និងទទួលវិញ្ញាបនបត្រ អំពីការទទួលវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធណាមួយ (មាត្រា ៥២) | ពី 500,000 ទៅ 2,000,000 |
| 25 | ការប្រើពាក្យស្តង់ដារកម្ពុជា ឬអក្សរកាត់ ISC (មាត្រា ៥៣) | ពី 500,000 ទៅ 2,000,000 |
| 26 | ការមិនបានស្នើសុំអាជ្ញាប័ណ្ណឡើងវិញ ពេលមានការកំណត់ស្តង់ដារថ្មី ឬប្រើហួសកាលបរិច្ឆេទកំណត់ (មាត្រា ៥៤) | ពី 1,000,000 ទៅ 5,000,000 |
| 27 | ការបិទសញ្ញាស្តង់ដារក្លែងបន្លំលើផលិតផល ឬប្រព័ន្ធណាមួយ (មាត្រា ៥៥, មាត្រា ៥៦) | ពី 2,000,000 ទៅ 6,000,000 |
| 28 | ការបោះពុម្ព ឬថតចម្លងឯកសារស្តង់ដារកម្ពុជា ដោយគ្មានការអនុញ្ញាត (មាត្រា ៥៨) | ពី 2,000,000 ទៅ 6,000,000 |
| 29 | ការមិនមានបិទសញ្ញាស្តង់ដារ ឬគ្មានអាជ្ញាប័ណ្ណ ឬមិនអនុលោមតាមស្តង់ដារបញ្ជាលើផលិតផល (មាត្រា ៥៩) | ពី 2,000,000 ទៅ 24,000,000 |
| 30 | ការប្រើ ឬបិទសញ្ញាស្តង់ដារលើអាជ្ញាប័ណ្ណដែលត្រូវបានលុបចោល ឬព្យួរ ឬដកហូត (មាត្រា ៦០) | ពី 2,000,000 ទៅ 24,000,000 |
| 31 | ការក្លែងបន្លំប្រើវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងណាមួយ ដែលត្រូវបានព្យួរ ឬដកហូត (មាត្រា ៦១) | ពី 2,000,000 ទៅ 24,000,000 |
| 32 | ជនណាដែលរារាំងអធិការក្នុងពេលបំពេញភារកិច្ច (មាត្រា ៦៥) | ពី 1,000,000 ទៅ 5,000,000 |
| 33 | ជនណាដែលក្លែងបន្លំខ្លួនជាអធិការ (មាត្រា ៦៦) | ពី 500,000 ទៅ 2,000,000 |
| **គ. បទល្មើសដែលចែងក្នុងច្បាប់ ស្តីពីការហាមឃាត់អាវុធគីមី** | | |
| 34 | ការផលិត ទិញ លក់ កាន់កាប់ កែច្នៃ ទទួល ផ្ទេរ រក្សាទុក ដឹកជញ្ជូនឆ្លងកាត់ ឬប្រើប្រាស់សារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ដោយគ្មានលិខិតអនុញ្ញាត (មាត្រា ២៨) | ពី 20,000,000 ទៅ 50,000,000 |

| ល.រ | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| **ឃ. បទល្មើសដែលចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងអាស៊ីដខ្លាំង** | | |
| 35 | អំពើផលិត កែច្នៃ នាំចូល នាំចេញ វេចខ្ចប់ ដឹកជញ្ជូន យកតាមខ្លួន ចែកចាយ លក់ ទិញ រក្សាទុក និងប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដោយគ្មានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ឬមិនគោរពតាមការកំណត់របស់បទដ្ឋានគតិយុត្ត ដែលមានទម្ងន់ក្រោម ៥០០ក្រាម (មាត្រា ១៤ ចំណុចទី១) | ពី 500,000 ទៅ 1,500,000 |
| 36 | អំពើផលិត កែច្នៃ នាំចូល នាំចេញ វេចខ្ចប់ ដឹកជញ្ជូន យកតាមខ្លួន ចែកចាយ លក់ ទិញ រក្សាទុក និងប្រើប្រាស់អាស៊ីដខ្លាំងគ្រប់ប្រភេទ ដោយគ្មានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាត ឬមិនគោរពតាមការកំណត់របស់បទដ្ឋានគតិយុត្ត ដែលមានទម្ងន់ចាប់ពី ៥០០ក្រាម ឡើងទៅ (មាត្រា ១៤ ចំណុចទី២) | ពី 1,500,000 ទៅ 10,000,000 |
| 37 | អំពើផលិតម្ហូបអាហារ ឬការអនុញ្ញាតឱ្យផលិតម្ហូបអាហារ ដោយប្រើអាស៊ីដខ្លាំងខុសពីបទដ្ឋានបច្ចេកទេស (មាត្រា ២៣) | ពី 2,000,000 ទៅ 10,000,000 |
| **ង. បទល្មើសដែលចែងក្នុងច្បាប់ ស្តីពីមាត្រាសាស្ត្រកម្ពុជា** | | |
| 38 | ជនណាដែលប្រើប្រាស់ ឬ កាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្មនូវឧបករណ៍មាត្រាសាស្ត្រដែលមិនមានពាណិជ្ជសញ្ញា ត្រូវទទួលការព្រមាន ឬពិន័យអន្តរការណ៍ក្នុងមួយគ្រឿង (មាត្រា ៣៩) | ពី 10,000 ទៅ 500,000 |
| 39 | ជនណាដែលលក់ ដាក់តាំងដើម្បីលក់ ដើម្បីចែកចាយ ឬដើម្បីផ្តល់នូវឧបករណ៍មាត្រាសាស្ត្រដែលមិនមានពាណិសញ្ញា ត្រូវទទួលការពិន័យអន្តរការណ៍ក្នុងមួយគ្រឿង (មាត្រា ៤០) | ពី 50,000 ទៅ 1,000,000 |
| 40 | ជនណាដែលប្រើប្រាស់ ឬកាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជកម្ម ឬក៏ដាក់តាំងដើម្បីលក់ ឬដើម្បីចែកចាយ នូវឧបករណ៍មាត្រាសាស្ត្រ ដែលមិនបានដាក់សញ្ញាត្រួតពិនិត្យ ដោយមន្ត្រីត្រួតពិនិត្យ ត្រូវទទួលការព្រមាន ឬពិន័យអន្តរការណ៍ក្នុងមួយគ្រឿង (មាត្រា ៤១) | ពី 10,000 ទៅ 500,000 |
| 41 | ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ចំពោះជនណាដែល ÷<br>ក- នាំចូល និង/ ឬផលិតឧបករណ៍មាត្រាសាស្ត្រ ដោយមិនអនុវត្តតាមគំរូដែលអនុម័តពីមុន និង រង្វាស់រង្វាល់ ឬគ្មានការអនុម័តគំរូ ឬ<br>ខ-ផលិតនិង/ ឬជួសជុលឧបករណ៍មាត្រាសាស្ត្រ ដែលគ្មានអាជ្ញាប័ណ្ណ ដែលចេញដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ឬ<br>គ- កាន់អាជ្ញាប័ណ្ណ តែបំពានលើលក្ខខណ្ឌ ដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណ។ ករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង (មាត្រា ៤២) | ពី 1,000,000 ទៅ 5,000,000 |

| ល.រ | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| 42 | ត្រូវពិន័យជាប្រាក់ ចំពោះជនណាដែលនាំចូល និង/ឬផលិតឧបករណ៍មាត្រាសាស្ត្រ ដោយប្រើពាណិជ្ជសញ្ញាក្លែងក្លាយ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ទ្វេដង (មាត្រា ៤៣) | ពី 1,000,000<br>ទៅ 5,000,000 |
| 43 | ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ចំពោះជនណាដែល ÷<br>ក-ប្រើប្រាស់ ឬកាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឬលក់ដាក់តាំង និងដើម្បីលក់ ឬដើម្បីចែកចាយនូវឧបករណ៍មាត្រាសាស្ត្រ ដែលមានពាណិជ្ជសញ្ញាដែលខ្លួនបានដឹងថាជាពាណិជ្ជសញ្ញាក្លែងក្លាយ ឬ<br>ខ-ដកចេញ ឬប្តូរសញ្ញាត្រួតពិនិត្យ ដែលបានដាក់ដោយមន្ត្រីត្រួតពិនិត្យលើឧបករណ៍មាត្រាសាស្ត្រ ហើយដាក់បញ្ចូលសញ្ញានោះលើឧបករណ៍មាត្រាសាស្ត្រផ្សេងទៀត។<br>ក្នុងករណីមិនរាងចាល ត្រូវពិន័យជាប្រាក់ទ្វេដង | ពី 1,000,000<br>ទៅ 5,000,000 |
| 44 | ត្រូវពិន័យជាប្រាក់ ចំពោះជនណាដែល÷<br>ក-បង្កើន បន្ថយ ឬបន្លំទម្ងន់ ឬរង្វាស់រង្វាល់ឧបករណ៍មាត្រាសាស្ត្រដែលបានដាក់សញ្ញាត្រួតពិនិត្យរួច ឬ<br>ខ-ប្រើប្រាស់ ឬកាន់កាប់សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពពាណិជ្ជកម្ម ឬលក់ដាក់តាំង ដើម្បីលក់ ឬដើម្បីចែកចាយនូវឧបករណ៍មាត្រាសាស្ត្រ ដែលខ្លួនបានដឹងថាបានបង្កើន បន្ថយ ឬបន្លំ។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ទ្វេដង | ពី 1,000,000<br>ទៅ 5,000,000 |
| 45 | ត្រូវពិន័យជាប្រាក់ ចំពោះជនណាដែល÷<br>ក-ធ្វើសេចក្តីបញ្ជាក់ដោយក្លែង មិនត្រឹមត្រូវឬ មិនពិតអំពីលេខ បរិមាណរង្វាស់រង្វាល់ ឬគណនា ថ្លៃសេវាកម្ម ដែលខ្លួនត្រូវផ្តល់ទៅតាមទម្ងន់ ឬរង្វាស់រង្វាល់ដែលបានព្រមព្រៀមគ្នា<br>ខ-លក់ ឬប្រគល់ទំនិញទៅឱ្យអ្នកទិញដោយមានបរិមាណ ឬរង្វាស់រង្វាល់តិចជាងបរិមាណដែលបានព្រមព្រៀងគ្នា។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ទ្វេដង | ពី 1,000,000<br>ទៅ 5,000,000 |
| 46 | ជនណាដែលផ្គត់ផ្គង់ លក់ ឬដាក់តាំងលក់នូវទំនិញវេចខ្ចប់ដែលបំភាន់អំពីលក្ខណៈទម្ងន់ ឬរង្វាស់រង្វាល់ ត្រូវពិន័យជាប្រាក់។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និង/ឬពិន័យជាប្រាក់ទ្វេដង | ពី 1,000,000<br>ទៅ 5,000,000 |

| ល.រ | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ ដែលត្រូវពិន័យ (រៀល) |
|---|---|---|
| 47 | អ្នកនាំចូលទំនិញ ឬអ្នកផលិតទំនិញវេចខ្ចប់ដែល÷<br>ក- នាំចូល ឬវេចខ្ចប់ទំនិញជាកញ្ចប់ផ្ទុយនឹងការតម្រូវនៃកថាខណ្ឌ នៃមាត្រា៣៣ នៃច្បាប់នេះ<br>ខ- ខកខានមិនបានដាក់សញ្ញាជាឯកតាដែលអនុញ្ញាតនៅលើសម្ភារៈវេចខ្ចប់នូវចំនួនទម្ងន់សុទ្ធឬរង្វាស់រង្វាល់ ដែលមានបញ្ជាក់លើសម្ភារៈវេចខ្ចប់នៅក្នុងកញ្ចប់នោះ ឬ<br>គ- ខកខានមិនបានបង្ហាញឈ្មោះ និងអាសយដ្ឋានរបស់អ្នកផលិត ឬអ្នកនាំចូល ឬសញ្ញាសម្គាល់សម្រាប់កំណត់អត្តសញ្ញាណនៃឈ្មោះ និងអាសយដ្ឋាន។ ត្រូវពិន័យអន្តរការណ៍ជាប្រាក់។ ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង ហើយទំនិញដែលជាកម្មវត្ថុនៃបទល្មើសត្រូវរឹបអូស (មាត្រា ៤៨) | ពី 1,000,000<br>ទៅ 5,000,000 |
| 48 | ជនណាដែលលក់ ឬដាក់លក់នូវទំនិញវេចខ្ចប់ដែលមិនមានដាក់ចំនួនវេចខ្ចប់ ដែលមិនមានដាក់ចំនួនទម្ងន់ឬរង្វាស់រង្វាល់លើសម្ភារៈវេចខ្ចប់នូវឯកតាដែលមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ត្រូវព្រមាន ឬពិន័យអន្តរការណ៍ជាប្រាក់ (មាត្រា ៤៩) | ពី 10,000<br>ទៅ 500,000 |
| 49 | ជនណាដែលរារាំង ឬបដិសេធមិនឱ្យមន្ត្រីត្រួតពិនិត្យអនុវត្តសិទ្ធិក្នុងប្រតិបត្តិការដែលមានចែងក្នុងច្បាប់នេះ ត្រូវព្រមាន ឬពិន័យអន្តរការណ៍ជាប្រាក់។ ក្នុងករណីមិនរាងចាល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង (មាត្រា ៥០) | ពី 1,000,000<br>ទៅ 5,000,000 |
| 50 | ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលកាន់កាប់ ដើម្បីប្រើប្រាស់ ជួល ឬចែកចាយនូវឧបករណ៍មាត្រាសាស្ត្រត្រូវមកបំពេញបែបបទ ដើម្បីសុំការពិនិត្យផ្ទៀងផ្ទាត់ និងដាក់សញ្ញាត្រួតពិនិត្យលើកដំបូងដោយមន្ត្រីមានសមត្ថកិច្ចក្នុងរយៈពេលមិនលើសពី ៦(ប្រាំមួយ)ខែ បន្ទាប់ពីពេលដែលច្បាប់នេះចូលជាធរមាននៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីមិនគោរពតាមបទប្បញ្ញត្តិនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ (មាត្រា ៥៦) | ពី 50,000<br>ទៅ 500,000 |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៤៤...ឧស.ភ.ប.ក-០៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំពង្រីកបន្ថែមអគារផលិតកម្មរោងចក្រ ផលិតស្បែកជើង នៅលើទីតាំងថ្មី របស់ក្រុមហ៊ុន ជូ ហួយ ហ្វ៊ូតវៃ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ជូ ហួយ ហ្វ៊ូតវៃ (JUHUI FOOTWEAR CO., LTD.) តំណាងដោយ លោក MU, HSIN-YUAN បង្កើតសាខារោងចក្រ ផលិតស្បែកជើង ដែលមានទីតាំងស្ថិតនៅ ភូមិអំពិលធំ ឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ស្បែកជើង | ១៥២០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ ៖** "រោងចក្រផលិតស្បែកជើង ជូ ហួយ ហ្វិតវែ សាខាទី១"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។៧/៧

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ចាម និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តកំពង់ចាម
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៤៣...ឧស.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៥

## ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ កែច្នៃដំឡូងមី សណ្តែកដី និងគ្រាប់ស្វាយចន្ទី របស់ក្រុមហ៊ុន ជីនរី អ៊ិនវេសមេន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ជីនរី អ៊ិនវេសមេន (ខេមបូឌា) ខូអិលធីឌី (JINRI INVESTMENT (CAMBODIA) Co., Ltd.) តំណាងដោយ លោក ZHAN HONGYANG បង្កើតរោងចក្រ កែច្នៃដំឡូងមី សណ្តែកដី និងគ្រាប់ស្វាយចន្ទី ដែលមានទីតាំងស្ថិតនៅ ភូមិកន្ទោកជើង សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១-គ្រាប់ស្វាយចន្ទី | ១០៣០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

២-សណ្តែកដី ១០៣០
៣-ដំឡូងមីក្រៀម ១០៣០

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការ ដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ "រោងចក្រកែច្នៃដំឡូងមី សណ្តែកដី និងគ្រាប់ស្វាយចន្ទី ជីនវី អ៊ិនវេសមេន (ខេមបូឌា) ខូអិលធីឌី"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។/៧

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៤៤...ឧស.ភឧ.ក្រភ-០៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៥

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតពង្រីកផលិតកម្ម កាត់ដេរសម្លៀកបំពាក់ លើទីតាំងថ្មី របស់ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី.ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី (CAMBO HANDSOME LTD.) តំណាងដោយ លោក LEE SINJAE បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងជ្រៃ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ ខេមបូ ហ៊ែនសាំ អិលធីឌី "សាខាទី២" "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។៕

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**សាត សាមី**

**បម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលារាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ